**ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០១២

## ជប៉ុនផ្តល់ ៧៤,៣៣៣ ដុល្លារអាមេរិក សម្រាប់ការពង្រីកបន្ទប់សម្រាលក្នុងមណ្ឌលសុខភាព

តាមរយៈកម្មវិធីគម្រោងជំនួយឥតសំណង សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណេ*) រដ្ឋាភិបាលជប៉ុនបានផ្តល់ជំនួយដែលមានទឹកប្រាក់សរុបចំនួន ៧៤,៣៣៣ ដុល្លាអាមេរិកដល់ People in Need សម្រាប់គម្រោងពង្រីកបន្ទប់សម្រាលក្នុងមណ្ឌលសុខភាពចំនួន៨ ក្នុងខេត្តតាកែវ។ កិច្ចសន្យាផ្តល់ជំនួយនេះ ត្រូវបានចុះហត្ថលេខាថ្ងៃនេះដោយ ឯកឧត្តម លោក ម៉ាសាហ្វុមី គូរ៉ូគី ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា និង លោក SCHMIED Petr ប្រធានបេសកម្ម People in Need ក្នុងព្រះរាជាណាចក្រកម្ពុជា នៅស្ថានទូតជប៉ុន។

ដើម្បីបង្កើនសេវាថែទាំសុខភាពមាតានិងទារក "People in Need"នឹងសាងសង់បន្ទប់មុននិងក្រោយសម្រាលក្នុងមណ្ឌលសុខភាពចំនួន៨ក្នុងខេត្តតាកែវ សម្រាប់គម្រោងពង្រីកបន្ទប់សម្រាលដែលមានស្រាប់។ គម្រោងនេះនឹងធ្វើឲមាតាយ៉ាងហោចណាស់ ១,៨០០នាក់ទទួលបានសេវាសុខាភិបាលត្រឹមត្រូវនៅមុននិងក្រោយពេលសម្រាលដែលយើងរំពឹងថានឹងរួមចំនែកកាត់បន្ថយអត្រាមរណៈមាតានិងទារកក្នុងប្រទេសកម្ពុជា។

កម្មវិធីគម្រោងជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (*ជំនួយគូសាណូណេ*) របស់រដ្ឋាភិបាលជប៉ុនបានចាប់ផ្តើមតាំងពីឆ្នាំ១៩៩១ដើម្បីគាំទ្រសកម្មភាពក្នុងកិច្ចខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍន៍ និង ស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកំរិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះ ពីកត្តាមួយចំនួនដូចជាភាពក្រីក្រ និង ភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជិវិតនិងសេចក្តីថ្លៃថ្នូររបស់ពួកគេក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៤៧លានដុល្លាអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និង អង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន ៤៦១នៅទូទាំងប្រទេស។

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*

*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*

*អ៊ីមែល: eco.jpn@.pp.mofa.go.jp*

*គេហទំព័រ: http://www.kh.emb-japan.go.jp*